# រឿង មហាចោរនៅទល់ដែន

## ភាគទី៤៣ (ស្នេហាលើទូក)

នៅក្នុងបន្ទប់មួយដ៏ធំល្វឹងល្វើយ ភ្ញៀវទាំងអស់អង្គុយលើកៅអីត្រៀបត្រាមើលស្រីរាំក្បាច់។ សម្លៀកបំពាក់នៃភ្ញៀវទាំងនោះ មានភាពរុងរឿងជាអនេកប្បការប្រកបដោយពណ៌ខុសៗគ្នារលើបរលង់។ ភរិយាអ្នកធំខ្លះ ប្រដាប់ដោយមាសពេជ្រ តាំងពីកដើងរហូតដល់ចុងសក់អង្គុយធ្វើមុខញញឹមប្រិមប្រិយយ៉ាងឧឡារឹក។ នៅកៅអីធំមួយដ៏រុងរឿងកណ្ដាលជួរខាងមុខព្រះកម្ពុតជាកិត្តិយស។ ខាងស្ដាំតស្សរជនជាន់ខ្ពស់បំផុតនោះ មានព្រះនាងខត្តិយាណីកែវមណីដែលត្រូវគ្រឿងខាងក្រៅមើលឃើញសាច់ថ្វាម៉ដគួរចាប់ចិត្តលើអ្នកផង។ ខាងឆ្វេងព្រះកម្ពុតកាមាអង្គុយជិតនៅស្ងៀមតែជិតជ្រៅ។ ស្រីៗអ្នករាំចេញមកត្រៀបត្រាលើកដៃរេរាំបន្ទន់ខ្លួនរត់លោតទៅតាមចង្វាក់ភ្លេងដ៏ស្រស់អស្ចារ្យ គួរសរសើរដល់សិល្បៈខ្មែរក្រៃពេក។ សូរភ្លេងរបាំ និងកាយវិការរបស់នារីយើង នាំចិត្តអោយរំភើបស្ញប់ស្ញែងដល់ភាពរុងរឿងនៃអារ្យធម៌យើង។ ភ្លេងនោះរបាំនោះធ្វើឲ្យនាយអារុណនិងនាយវីរៈភ្លេចការដែលខ្លួនមកធ្វើអស់ចំនួនមួយស្របក់ធំ។ នាយវីរៈញាក់មុខដាក់នាយអារុណ ក្រោយប្រឡោះបង្អួចលើឡៅមួយពីលើហ្វូងជនអ្នកមើនិងជនអ្នករាំឲ្យគេមើលនេះ។ នាយអារុណញាក់មុខជាសញ្ញាឆ្លើយតបទៅសហជាវិនខ្លួនវិញ។ ស្រីៗដែលរេរាំកំពុងលុតក្រាបពីមុខព្រះកម្ពុត ដែលមួយពេលនោះហាក់អណ្ដែកខ្លួនទៅក្នុងអាកាស រួចដែលបណ្ដោយចិត្តទៅក្នុងសេចក្ដីប្ញើងឥតនឹកនាថាពុំគួរឲ្យគេធ្វើដូច្នោះឡើយ។

ក្នុងពេលដែលព្រះកម្ពុត ព្រះនាងខត្តិយាណី និងកាមា បានត្រូវគេលើកផុតអស់មនុស្សលើលោកនេះ សម្រែកអារុណដែលយិតធ្នូរបំដើមទ្រូង ព្រះកម្ពុតដ៏លាន់ឮឡើង។

បិសាចទាំងអស់ ឈប់សប្បាយនៅឲ្យស្ងៀម ឬមួយកម្ពុតស្លាប់ក្នុងពេលនេះ។ ហាស់ៗៗ សប្បាយណាស់ ក្នុងពេលដែលខ្មែររងទុក្ខ។

អ្នកទាំងអស់គ្នាស្រឡាំងកាំង។ ព្រះកម្ពុតភិតភ័យតក្កមា។ ព្រះនាងខត្តិយាណីមុខឡើងស្លាំង។ កាមាខាំធ្មេញ សម្លឹងមើលអារុណស្ទើរផ្ទុះ។

អត្ថបទដោយ៖ មាស សុភាព

គ្មានអ្នកណាមួយកំរើករពើកឡើយ។ ស្រីៗដែលកំពុងរាំក៏ឈប់ស្ងៀមស្ងាត់។

ព្រះកម្ពុតនិយាយញ័រៗឡើងថា:

អ្នកឯងជាអ្នកណា? មកពីណា? មានការអ្វី?

ហាសៗ! យើងៗ ជាអារុណមកពីទល់ដែនមកដោះលែងមានន្ទ។ ស្ងៀមវីរៈចូលទៅយកសោគុកពីកម្ពុតមក!

វីរៈលោតផ្ទោតពីលើបង្អួចចុះមកក្រោម ធ្លាក់ខ្លួនទៅលើពូកមួយផ្ទាត់ខ្លួនលោតកំពស់ពីរម៉ែត្រធ្លាក់មកវិញ ញាំងរត់ទៅរកព្រះកម្ពុតឥតបង្អង់យូរឡើយ។

កាមាប្រានតុរលំប្រាវព្រួញរត់ពីដៃអារុណមកបុកតុដែលដួលឈឹប។ ការប្រឡូកគ្នាក៏ចាប់កើតមានឡើងមួយរំពេច។

អារុណបោះស្នាប្រូស លោតតាមបង្អួចមកដល់ដីកាប់ផ្ទាប់ៗភ្លាម។

ព្រះកម្ពុតចាប់ដៃនាងមណីឡើងជណ្តើរ។ កាមាថយខ្លួនក្រាកពីបន្ទប់សមរភូមិ។ តុទូល្អៗក្រឡាប់គ្រេងៗ គេឃើញអារុណ និងវីរៈវាយប្រហារយ៉ាងអង់អាចក្រោមចក្ខុរបស់ព្រះនាងមណីនិងព្រះកម្ពុត ដែលឥឡូវនេះញញឹមយ៉ាងពេញចិត្តនឹងពលទាហានខាងខ្លួន។ ព្រះនាងខត្តិយាណីចាប់ភ្ញឹកយ៉ាងខ្លាំងនឹងវីរបុរសទាំងពីរ ដែលពូកែស្ទិតស្ទាញវាយពលខាងនាងដួលត្រៀបត្រា។ នាងនឹកថា:

ជនអ្នកតស៊ូពូកែមែន! ខាងឯងមានគ្នាច្រើនដូចជាគួរឱ្យខ្មាស់ទេវតាណាស់។

អារុណវាយថយៗ ស្រាប់តែងាកក្រោយទង្គិចខ្នងវីរៈ។ អារុណស្រែកឡើងថា:

មាត់ទ្វារធំ។

វីរៈសើចវាយថយ រួចជនទាំងពីរបិទទ្វារគ្រឹប។

ព្រះកម្ពុតឃើញដូច្នោះមុខឡើងស្វាំងញ័រដៃទទ្រើក ស្រែកយ៉ាងអស់ទំហឹងថា:

ចាប់វាឲ្យបាន!

អត្ថបទដោយ៖ មាស សុភាព

*កងទាហានបុកទ្វារនឹងស្មារប៉ាំងៗ តែទ្វារពុំរបើកសោះ។*

*អារុណ និងវីរៈស្ទុះទៅទ្វារគុក។ អ្នកយាមកាំងស្រឡាំងកាំង ត្រូវវីរៈទាត់មួយជើងផ្ងងដួលផ្ងារ ពោះស្រែកថា:*

*ជួយផង! ជួយផង!*

*អារុណទៅដល់គុកទាញទ្វារអឺសៗអស់ទំហឹងតែពុំរួចសោះ។ មានន្ទជួយជាក់ទ្វារពី ក្នុងមកដែរ តែពុំរួចទៀតព្រោះជាប់សោរ។*

*វីរៈមកដល់បង្ហាញសោរ។ អារុណកញ្ឆក់សោភ្លាមចាក់។ ជនទាំងបីរត់ទៅបើកទ្វារគុក ឯទៀតទាំងអស់។ អ្នកទោសស្រែកទ្រហ៊ោឡើងថា ជយោ! ជយោ! លាន់ឮគ្រេវៗ។*

*ខាងទាហានរាប់រយនាក់ ក៏ស្ទុះស្រមកដល់។ សង្គ្រាមផ្ទុះឡើងរឹតតែខ្លាំងទៅៗ។*

*នាយកោប មហាកាល អគ្គី មានន្ទ អារុណ វីរៈ វាយឆ្មើតជាងគេសើចបណ្តើរ ញាក់មុខ ដាក់គ្នាបណ្តើរ។ នាយកោបស៊ីចេកមួយស្និតផងវាយផង។*

*មានន្ទស្រែក:*

*តស៊ូអោយជាប់ដៃកនយើង!*

*រួចទៅខ្សឹបប្រាប់អារុណឲ្យប្រាប់តៗទៅទៀតថា:*

*យប់នេះជួបគ្នានៅភូមិភ្លៀត។*

***(សូមរង់ចាំតាមដានភាគទី៤៤ នៅសប្តាហ៍ក្រោយ)***



*អត្ថបទដោយ៖ មាស សុភាព*